**ស្ថានទូតអូស្ត្រាលី**

**ប្រចាំទីក្រុងភ្នំពេញ**

# សេចក្តីប្រកាសព័ត៌មាន

## អូស្ត្រាលីធ្វើការដើម្បីអភិរក្សមរតកវាយនភ័ណ្ឌបុរាណកម្ពុជា

ឯឧត្តម **ហ៊ឹម ឆែម** រដ្ឋមន្ត្រី ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និង លោកស្រី **ម៉ាហ្គារ៉េត អាដាមសុន** ឯកអគ្គរាជទូតអូស្ត្រាលី បានបើកសម្ពោធការបោះពុម្ពផ្សាយសៀវភៅដែលមានចំណងជើងថា *“វាយនភ័ណ្ឌដែលប្រកបដោយរូបភាពនៃកម្ពុជា: ជាបង្អួចចូលទៅក្នុងវប្បធម៌ប្រវត្តិសាស្ត្រកម្ពុជា”* នៅសារមន្ទីរជាតិនាថ្ងៃនេះ ដោយមានវត្តមានរបស់អ្នកនិពន្ធ **ហ្គីល ហ្គ្រីន** ផងដែរ ។

លោកស្រី **ម៉ាហ្គារ៉េត អាដាមសុន** ឯកអគ្គរាជទូតអូស្ត្រាលីបានមានប្រសាសន៍ថា ”ខ្ញុំសង្ឃឹមថា តាមរយៈសៀវភៅរបស់ **ហ្គីល ហ្គ្រីន** នេះ មានមនុស្សជាច្រើនទៀតនឹងបានដឹងហើយនិងពេញចិត្តចំពោះប្រឌិតញ្ញាណ និងជំនាញដ៏អស្ចារ្យ ដែលសំដែងឡើងដោយអ្នកត្បាញកម្ពុជា។ បេតិកភ័ណ្ឌដែលមានជីវិតរបស់កម្ពុជា ក៏ដូចជាអង្គរវត្តដែរ គួរតែទទួលបានការអភិរក្ស និងការសិក្សា ដើម្បីឱ្យមនុស្សគ្រប់គ្នាបានយល់ និងប្រើប្រាស់ ។”

លោកស្រី **ហ្គ្រីន** គឺជាអ្នកមានកិត្តនាមលើប្រធានបទវាយនភ័ណ្ឌកម្ពុជា។ លោកស្រីបានធ្វើការសិក្សាលើវាយនភ័ណ្ឌកម្ពុជា និងប្រពៃណីតំបាញអស់រយៈពេល១៥ឆ្នាំមកហើយ ហើយបានបង្រៀន និងផ្សព្វផ្សាយអំពីប្រធានបទនេះយ៉ាងទូលំទូលាយ។ សៀវភៅតំបូងរបស់គាត់ មានចំណងជើងថា *“វាយនភ័ណ្ឌប្រពៃណីកម្ពុជា”* ដែលបានទទួលពានរង្វាន់ឆ្នាំ២០០៤ ដោយសង្គមវាយនភ័ណ្ឌអាមេរិក ។

សៀវភៅថ្មីនេះ មានការប្រមូលផ្តុំយ៉ាងទូលំទូលាយនូវរូបភាពនៃការដាក់ព្យូរសូត្រដែលកម្របានឃើញ ហើយការប្រមូលមួយផ្នែកធំបានមកពីសារមន្ទីរជាតិ។ លោកស្រី **ហ្គ្រីន** បានវិភាគអត្ថន័យលំអិតនៃការរៀបរាប់នៅលើសំលៀកបំពាក់ដោយរាប់បញ្ចូល ទាំងពិណដ៏ស្រស់ត្រកាល នៃនាវា បក្សាបក្សី សត្វពាហៈណៈ និងដើមឈើជាដើម ។ លោកស្រីក៏បានពន្យល់ផងដែរ អំពីវិធីសាស្ត្រយ៉ាងស្មុគស្មាញ ដែលប្រើប្រាស់ដោយអ្នកតំបាញកម្ពុជាដើម្បីផលិតជារូបភាពយាងពិតប្រាកដ ។

### អំណោយរបស់លោកមែនតុនដល់សារមន្ទីរជាតិ

លោកស្រី **ម៉ាហ្គារ៉េត អាដាមសុន** ឯកអគ្គរាជទូតអូស្ត្រាលី បានលើកសរសើរចំពោះអំណោយដ៏សប្បុរសនូវវាយនភ័ណ្ឌរបស់កម្ពុជាជូនដល់សារមន្ទីរជាតិ ដែលផ្តល់ដោយអតីតអ្នកការទូតអូស្ត្រាលី គឺលោក **ណេិល មែនតុន** ។ វាយនភ័ណ្ឌដែលបានផ្តល់ជូនមួយចំនួនត្រូវបានដាក់តាំងបង្ហាញនៅក្នុងពិធីសម្ពោធនេះផងដែរ ។

Villa 11, R.V. Senei Vinnavaut Oum (Former St 254), Chaktaumuk Quarter, Daun Penh District, Phnom Penh City, Kingdom of Cambodia
Telephone: 855 23 213470 Facsimile: 855 23 213413

លោក **ម៉ែនតុន** បានប្រមែប្រមូលវាយនភ័ណ្ឌប្រពៃណីក្នុងពេលដែលគាត់បំពេញការងារនៅទីក្រុងភ្នំពេញក្នុងអំឡុងឆ្នាំ១៩៦០ និងដើមឆ្នាំ១៩៧០ ។ គំនូរជាច្រើនងាយនឹងរកបាននៅពេលនោះ តែត្រូវបាត់ទៅវិញ ។ ដោយប្រគល់វាយនភ័ណ្ឌទាំងនេះជូនសារមន្ទីរជាតិវិញ លោក **ម៉ែនតុន** បានជួយអភិរក្សដែលមានលក្ខណៈផុយស្រួយនៃបេតិកភ័ណ្ឌដ៏មានតំលៃ សំរាប់មនុស្សជំនាន់ក្រោយ ។

*ទំនាក់ទំនងសារព័តមានៈ លោកស្រី **ហ៊ីយូណា ខស្មូ** លេខាទី ១ : ០២៣ ២១៣ ៤៧០*

ស្ថានទូតអូស្ត្រាលី ប្រចាំទីក្រុងភ្នំពេញ

២៥ វិច្ឆិកា ២០០៨